- បានទ្រង់យល់ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៩៩៥

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **នា ចាំរ៉ាត់** ជាសមាជិក នៃក្រុមប្រឹក្សាភិបាល នៃមូលនិធិសង្គម ជំនួសឯកឧត្តម **ហេង ខន្សម៉ុនឆាត**

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះហស្ដលេខា ។

**ព្រះហស្ដលេខា**

**នរោត្ដម សីហនុ**

* * *

# II.ឌ.ស្ដីការគណៈរដ្ឋមន្ត្រី

## ១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥

## អនុក្រឹត្យលេខ ៤០ អនក្រ

## ស្ដីពីលក្ខន្តិកៈរបស់សាលាគូមិន្ទរដ្ឋបាល

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញកិច្ចព្រមព្រៀង ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ រវាងរដ្ឋាភិបាលសាធារណរដ្ឋបារាំង និង រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំឡើងវិញនូវសាលាភូមិន្ទរដ្ឋបាលប្រចាំនៅកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជា លេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមស្មារតីសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៥

## សម្រេច

**មាត្រា ១ :** សាលាភូមិន្ទរដ្ឋបាល ជាភាសាបារាំងហៅថា Ecole Royal d'Aministration សរសេរអក្សរកាត់ ERA ត្រូវបានបង្កើតឡើងវិញតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥ ។ សាលាភូមិន្ទរដ្ឋបាល ជាស្ថាប័នមួយដែលមានបុគ្គលិកលក្ខណៈគតិយុត្តិ ហើយចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ។ សាលាភូមិន្ទរដ្ឋបាល មានថវិកាពិសេសមួយបញ្ចូលក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២ :** ទីស្នាក់ការរបស់សាលាភូមិន្ទរដ្ឋបាល តាំងនៅរាជធានីភ្នំពេញ ផ្លូវ ឧកញ៉ាញ៉ឹក ជូឡុង «អតីតលេខ ៤៦៦» ខណ្ឌចំការមន ។

**មាត្រា ៣ :** សាលាភូមិន្ទរដ្ឋបាលមានបេសកកម្មជ្រើសរើស បណ្តុះបណ្តាល និង វិក្រឹតការមន្ត្រីរាជការ ដែលត្រូវគ្រប់គ្រងការងារក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤ :** បញ្ជីនៃអង្គ ដែលសាលាភូមិន្ទរដ្ឋបាលត្រូវរៀបចំជ្រើសរើសបណ្តុះបណ្តាល ត្រូវកំណត់តាមបទបញ្ញត្តិនៃលក្ខន្តិកៈ ដែលគ្រប់គ្រងអង្គនានារបស់មន្ត្រីរាជការក្នុងព្រះរាជាណាចក្រកម្ពុជា ឬបើគ្មាន ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ១

## ការរៀបចំរបស់សាលាភូមិន្ទរដ្ឋបាល

**មាត្រា ៥ :** សាលាភូមិន្ទរដ្ឋបាល ថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតនៅក្រោមការដឹកនាំរបស់នាយកមួយរូប អមដោយក្រុមប្រឹក្សាភិបាលមួយ និងមានជំនួយពីនាយកសិក្សាមួយរូបទទួលបន្ទុកកិច្ចការគរុកោសល្យ ពីនាយកបច្ចេកទេសមួយរូប ឬច្រើនរូបទទួលបន្ទុកកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និង ការរៀបចំកម្មសិក្សា ។

**មាត្រា ៦ :** នាយកសាលា

- ទទួលខុសត្រូវលើការប្រព្រឹត្តទៅរបស់សាលា អនុវត្តតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល
- ទទួលមើលការគោរពវិន័យផ្ទៃក្នុងដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង
- រៀបចំថវិកា និង គណនេយ្យរដ្ឋបាល និង ហិរញ្ញវត្ថុរបស់សាលា
- បញ្ជាក្នុងការចំណាយសមស្របទៅតាមគម្រោងថវិកាប្រចាំឆ្នាំ
- ចាត់ចែងការប្រឡងប្រជែង និង ការប្រឡងនានាដោយរក្សាគោលការណ៍អនាមិកភាព និង ការកែដោយគ្រូពីរនាក់ ។
- តែងតាំងគ្រូបង្ហាត់ ក្រោយពីមានការយល់ព្រមពីគណៈកម្មាធិការអចិន្ត្រៃយ៍ ។
- ចាត់ចែងកម្មសិក្សា
- ជ្រើសរើសបុគ្គលិកបង្ហាត់បង្រៀនសំរាប់មុខវិជ្ជា និង រយៈពេលមានកំណត់ និង ភ្នាក់ងារប្រតិបត្តិ
- រៀបចំអង្គការលេខ រៀបចំការប្រព្រឹត្តទៅ និង ការគ្រប់គ្រងរបស់សាលា
- ដាក់ជូនក្រុមប្រឹក្សាភិបាល នូវរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសភាពការណ៍សតិអារម្មណ៍ និង ហិរញ្ញវត្ថុរបស់សាលា និង គម្រោងអភិវឌ្ឍន៍នានា
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងសាលាជាមួយផ្នែករដ្ឋបាល សហគ្រាស អង្គការវិជ្ជាជីវៈខ្មែរ ឬប្រទេសដទៃ ឬជាមួយអង្គការ និង ស្ថាប័នអន្តរជាតិ ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល និង ការអនុញ្ញាតពីនាយករដ្ឋមន្ត្រី ។

**មាត្រា ៧ :** ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សហប្រធាន |
| - តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មួយរូប | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ មួយរូប | សមាជិក |

–តំណាងក្រសួងហិរញ្ញវត្ថុ មួយរូប សមាជិក

–តំណាងក្រសួងយុត្តិធម៌ មួយរូប សមាជិក

–តំណាងក្រសួងអប់រំ យុវជន និងកីឡា មួយរូប សមាជិក

–តំណាងរដ្ឋលេខាធិការដ្ឋានទទួលបន្ទុកមុខងារសាធារណៈ មួយរូប សមាជិក

–ឥស្សរជនពីរូបជ្រើសរើសយោលទៅតាមគុណសម្បត្តិ សមាជិក

–នាយកសាលា សមាជិកពេញសិទ្ធិ

–នាយកការសិក្សា សមាជិកអញ្ជើញចូលរួម

ក្រុមប្រឹក្សាភិបាលជ្រើសរើសលេខាធិការមួយរូប ដែលអាចជ្រើសរើសក្នុងចំណោមបុគ្គលិកសាលា ។

**មាត្រា ៨ :** ប្រធាន និង សមាជិក នៃក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៩ :** ក្រុមប្រឹក្សាភិបាលជាអ្នក :

–យល់ព្រមលើបទបញ្ជាផ្ទៃក្នុង លើកម្មវិធីសិក្សា លើបែបបទចាត់ចែងការប្រឡង និងការប្រឡងប្រជែង លើសមាសភាពគណៈមេប្រយោគ ។

–យល់ព្រមលើគម្រោងថវិកា ។

–អនុញ្ញាតការបង្កើតមជ្ឈមណ្ឌលឧបសម្ព័ន្ធឯកទេស និង យល់ព្រមនូវគម្រោងនានានៃកិច្ចព្រមព្រៀង ដែលមានទំនាក់ទំនងដល់សាលាភូមិន្ទរដ្ឋបាល ទៅនឹងគ្រឹះស្ថាន ឬ ផ្នែកនានារបស់ជាតិ ឬ បរទេស ។

–ត្រួតពិនិត្យការគ្រប់គ្រងរបស់នាយកសាលា និង យល់ព្រមលើរបាយការណ៍ប្រចាំឆ្នាំរបស់នាយកសាលា ។

–ចាត់តាំងនៅក្នុងក្រុមប្រឹក្សា នូវគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ទទួលបន្ទុកធានារ៉ាប់រងដល់ដំណើរការកិច្ចការទូទៅ ។

–ហើយជាទូទៅ សំរេចលើរាល់បញ្ហាស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលា។

**មាត្រា ១០:** ក្រុមប្រឹក្សាភិបាលប្រជុំពីរដងក្នុងមួយឆ្នាំ តាមសម័យប្រជុំធម្មតានៅសប្តាហ៍ទីមួយ នាខែ ឧសភា និង ខែ កញ្ញា ។

ក្រុមប្រឹក្សាប្រជុំតាមសម័យប្រជុំវិសាមញ្ញ តាមសំណូមពររបស់ប្រធាន របស់នាយកសាលា ឬ របស់សមាជិកចំនួនពាក់កណ្តាលឡើងទៅ ។

ការកោះប្រជុំរបស់ប្រធាន ត្រូវមានភ្ជាប់របៀបវារៈ ។

**មាត្រា ១១:** ក្រុមប្រឹក្សាភិបាលអាចនឹងសំរេចធ្វើអ្វីបាន លុះណាតែមានអង្គប្រជុំនៃភាគច្រើនរបស់សមាជិក ។ សេចក្តីសំរេចធ្វើឡើងដោយមតិភាគច្រើននៃសមាជិកដែលមានវត្តមាន។ ក្នុងករណីបែងចែកសម្លេង គឺសម្លេងរបស់ប្រធានដែលមានឧត្តមានុភាព ។

មិនអនុញ្ញាតអោយមានតំណាងសមាជិកក្រុមប្រឹក្សា ។ ក្នុងករណីមានកៅអីទំនេរ ត្រូវតែងតាំងអ្នកជំនួសដែលត្រូវបន្តអាណត្តិរបស់អ្នកមុន ។

**មាត្រា ១២:** គណៈកម្មាធិការអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាភិបាល ដែលបញ្ជាក់ក្នុងមាត្រាទី ៩ រួមមាននាយកសាលា និង សមាជិកបួនរូប នៃក្រុមប្រឹក្សាដែលចាត់តាំងឡើងនៅផ្ទៃក្នុងរបស់ខ្លួន នៅសម័យប្រជុំសាមញ្ញនាខែ ឧសភា ។ នាយកសិក្សា ត្រូវបានអញ្ជើញអោយចូលរួមក្នុងពេលប្រជុំ ។

គណៈកម្មាធិការអចិន្ត្រៃយ៍ប្រជុំនៅសប្តាហ៍ទី ៤ នៃរៀងរាល់ខែ ។

គណៈកម្មាធិការរាយការណ៍ទៅក្រុមប្រឹក្សាភិបាលពីការងាររបស់ខ្លួន ។

## ជំពូកទី ២

## ការជ្រើសរើសចូលសាលាភូមិន្ទរដ្ឋបាល

**មាត្រា ១៣:** ការចូលរៀននៅសាលាភូមិន្ទរដ្ឋបាល ប្រព្រឹត្តទៅតាមការប្រឡងប្រជែង សំរាប់ការបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ និង មន្ត្រីមធ្យម ។ ការចាត់តាំងអាចធ្វើសំរាប់វគ្គសុក្រឹតការ ។

### ផ្នែកទី ១

### ការបណ្តុះបណ្តាលបឋម

**មាត្រា ១៤:** សេចក្តីសំរេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី កំណត់ចំនួនកន្លែងផ្តល់ដល់រាល់ការប្រឡងប្រជែង ព្រមទាំងលក្ខណ្ឌប្រឡង មុខវិញ្ញាសា និងសមាសភាពនៃគណៈមេប្រយោគ។

**មាត្រា ១៥:** មិនអនុញ្ញាតអោយបង្ហាញខ្លួនលើសពីបីដង ក្នុងការប្រឡងប្រជែងចូលជ្រើសរើសមន្ត្រីជាន់ខ្ពស់ ឬ មន្ត្រីមធ្យម ។

**មាត្រា ១៦:** សិស្ស មិនមែនជាមន្ត្រីដែលបានប្រឡងជាប់ចូលក្នុងសាលាមានគុណសម្បត្តិជាមន្ត្រីកម្មសិក្សា ។ សិស្សទាំងអស់នៅពេលចូលរៀនក្នុងសាលា ត្រូវចុះហត្ថលេខាថា យល់ព្រមបំរើរដ្ឋក្នុងរយៈពេល ៧ ឆ្នាំយ៉ាងតិចរាប់ពីពេលដែលខ្លួនបានត្រូវតែងតាំងមក។

**មាត្រា ១៧:** កិច្ចការសិស្សត្រូវមានលក្ខណៈជាអនាមិក ហើយត្រូវកែដោយគ្រូពីរនាក់ ។

**មាត្រា ១៨:** គណៈមេប្រយោគនៃការប្រឡងប្រជែងនីមួយ ។ អាចវាយតម្លៃដោយអធិបតេយ្យនូវចំនួនបេក្ខជនដែលត្រូវឆ្លងវិញ្ញាសាសួរផ្ទាល់មាត់ មុនពេលលើកអនាមិកភាពនៃកិច្ចការសិស្ស ។ ក្នុងករណីមិនដាច់ស្រេច សម្លេងប្រធានមេប្រយោគមានឧត្តមានុភាព ។

## ផ្នែកទី ២

## វគ្គ សុក្រឹតការ

**មាត្រា ១៩:** បញ្ជីនៃកម្មសិក្សាការី ដែលទទួលអោយចូលរៀនវគ្គសុក្រឹតការត្រូវកំណត់ដោយសេចក្តីសំរេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី យោងតាមសំណើរបស់រដ្ឋមន្ត្រីនានា និងផ្នែកដែលពាក់ព័ន្ធ ។

**មាត្រា ២០:** កម្មសិក្សាការីបានត្រូវដាក់ក្នុងស្ថានភាពផ្តាច់ចេញពីមុខងាររបស់ខ្លួន ក្នុងរយៈពេលសិក្សាវគ្គសុក្រឹតការ ។

# ជំពូកទី ៣

# សិក្ខាគារិកភាពនៅសាលាភូមិន្ទរដ្ឋបាល

## ផ្នែកទី ១

## ការបណ្តុះបណ្តាលបឋម

**មាត្រា ២១:** ការសិក្សាមានរយៈពេលពីរឆ្នាំ ។ រយៈពេលសិក្សារួមមានការសិក្សា និង ការធ្វើកម្មសិក្សា ដែលទុកជាវិញ្ញាសាសំរាប់ការចាត់ថ្នាក់ ។

**មាត្រា ២២:** កម្មវិធីសិក្សា និង កម្មវិធីកម្មសិក្សា ត្រូវរៀបចំឡើងដោយនាយកសាលាតាមការស្នើរបស់នាយកសិក្សា ។ កម្មវិធីនោះត្រូវមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។

**មាត្រា ២៣:** ការសិក្សាអាចបំពេញបន្ថែមនៅពេលចេញពីសាលា ដោយការបណ្តុះបណ្តាលឯកទេស ដើម្បីសំរេចអោយបានសមស្របទៅនឹងមុខងារ ។ ដូច្នេះត្រូវមានកិច្ចព្រមព្រៀងរវាងសាលាភូមិន្ទរដ្ឋបាល និងរដ្ឋបាលសាមី ដើម្បីធ្វើបែបបទបណ្តុះបណ្តាល។

## ផ្នែកទី ២

## វគ្គសុក្រឹតការ

**មាត្រា ២៤:** វគ្គសុក្រឹតការមានរយៈពេល ៩ ខែ ។ ក្នុងករណីចាំបាច់ ត្រូវធ្វើកម្មសិក្សាភាសាជាមុន ។ វគ្គសុក្រឹតការ មិនមានការចាត់ថ្នាក់នៅពេលចេញទេ ។

**មាត្រា ២៥:** កម្មសិក្សាការីដែលទទួលបានពិន្ទុលើសពីមធ្យមក្នុងពេលសិក្សា ត្រូវទទួលនូវវិញ្ញាបនបត្រសិក្សាមួយហើយអាចទទួលបាននូវការឡើងឋានន្តរសក្តិ ។

## ជំពូកទី ៤

## ការចាត់ថ្នាក់ពេលចេញពីសាលា

**មាត្រា ២៦:** សេចក្តីសំរេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បញ្ជាក់ពីអាជីពដែលបើកអោយមានដល់សិស្សមន្ត្រីជាន់ខ្ពស់ និង មន្ត្រីមធ្យម ពីការតែងតាំងគណៈមេប្រយោគ ទទួលបន្ទុករៀបចំការចាត់ថ្នាក់របស់សិស្សទាំងនោះ និង បញ្ជាក់ពីមុខ និង ចំនួនវិញ្ញាសា ។

ការចាត់ថ្នាក់ត្រូវរៀបចំទៅតាមពិន្ទុសរុប ទទួលបានដោយសិស្សម្នាក់ ៗ ដោយបូកបញ្ចូល គិតដល់មេគុណទៀតផង នូវពិន្ទុកម្មសិក្សា ពិន្ទុត្រួតពិនិត្យប្រចាំ និង ពិន្ទុប្រឡង ។

**មាត្រា ២៧:** សិស្សទាំងឡាយដែលបានមានឈ្មោះក្នុងបញ្ជីប្រឡងជាប់ជ្រើសរើសអង្គ រដ្ឋបាលរបស់ខ្លួនដែលគេនឹងត្រូវបំពេញការងារយោលទៅតាមលេខចាត់ថ្នាក់ ។

ពួកគេនឹងទទួលបានការតាំងស៊ុបក្នុងក្របខ័ណ្ឌ ក្រោយពីធ្វើកម្មសិក្សាសាកល្បងរួចមក ។

**មាត្រា ២៨:** មេប្រយោគមិនចុះឈ្មោះសិស្សដែលបានពិន្ទុក្រោមមធ្យម លើបញ្ជីចាត់ថ្នាក់ទេ ។

**មាត្រា ២៩:** សិស្សដែលមិនបានបញ្ចប់រយៈពេលសិក្សាដោយជោគជ័យ ដោយមានមូលហេតុអ្វីក៏ដោយមិនអាចទុកខ្លួនថា មានគុណសម្បត្តិជាអតីតសិស្សសាលាភូមិន្ទរដ្ឋបាលឡើយ។

## បទបញ្ញត្តិផ្សេង ៗ

**មាត្រា ៣០:** បទបញ្ជាផ្ទៃក្នុងដែលរៀបចំដោយនាយកសាលា ក្រោយពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល បញ្ជាក់នូវសិទ្ធិ និង ភាពតួកិច្ចនៃសិស្ស និង កម្មសិក្សាការី នូវលក្ខខណ្ឌនៃសិក្ខាគារិកភាព និង របបវិន័យ ។

**មាត្រា ៣១:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣២:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួងពាក់ព័ន្ធ នាយកសាលាភូមិន្ទរដ្ឋបាល និង ក្រុមប្រឹក្សាភិបាល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |